# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**សុន្ទរកថា**
**ឯកឧត្តមទេសរដ្ឋមន្ត្រី អៀង មូលី ប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍**

**ថ្លែងក្នុងឱកាសបើក**
**កិច្ចប្រជុំពេញអង្គអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ លើកទី១ ឆ្នាំ២០២៦**
**ថ្ងៃព្រហស្បតិ៍ ១១កើត ខែបឋមាសាឍ ឆ្នាំមមី អដ្ឋស័ក ពុទ្ធសករាជ២៥៧០**
**ថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០២៦ នៅវិមានមិត្តភាព នៃទីស្តីការគណៈរដ្ឋមន្ត្រី**

- សូមគោរពអង្គពិធីទាំងមូល
- ឯកឧត្តម លោកជំទាវ អនុប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍
- ឯកឧត្តម លោកជំទាវ ប្រធានគណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍ក្រសួង រដ្ឋលេខាធិការដ្ឋាន រាជធានី ខេត្ត និងភាកបាទក្រហមកម្ពុជា
- ឯកឧត្តម លោកជំទាវ លោក លោកស្រី នាងកញ្ញា ភ្ញៀវជាតិ និងអន្តរជាតិជាទីរាប់អាន!

ថ្ងៃនេះខ្ញុំមានកិត្តិយស និងក្តីសោមនស្សរីករាយបំផុតដែលបានដឹកនាំ **“កិច្ចប្រជុំពេញអង្គអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ លើកទី១ ឆ្នាំ២០២៦”** ស្របពេលដែលព្រះរាជាណាចក្រកម្ពុជាយើងត្រូវបានអង្គការសហប្រជាជាតិប្រកាសទទួលស្គាល់ជាប្រទេសមួយក្នុងតំបន់អាស៊ី-ប៉ាស៊ីហ្វិក ទទួលបានជោគជ័យក្នុងការសម្រេចបានគោលដៅ ៩៥-៩៥-៩៥ មុនកាលកំណត់។

**ក្នុងឱកាសនេះ ខ្ញុំសូមអង្គពិធីទាំងមូលទះដៃអបអរសាទរនូវសមិទ្ធផលដ៏ត្រចះត្រចង់របស់យើងទាំងអស់គ្នា!**

ក្នុងនាមថ្នាក់ដឹកនាំអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ និងក្នុងនាមខ្លួនខ្ញុំផ្ទាល់ ខ្ញុំសូមសម្តែងនូវការស្វាគមន៍យ៉ាងកក់ក្តៅបំផុត និងអំណរគុណយ៉ាងជ្រាលជ្រៅជូនចំពោះ ឯកឧត្តម លោកជំទាវ លោក លោកស្រី ភ្ញៀវជាតិ និងអន្តរជាតិទាំងអស់ដែលបានយកពេលវេលាដ៏មានតម្លៃអញ្ជើញចូលរួមក្នុងកិច្ចប្រជុំពេញអង្គលើកទី១ ឆ្នាំ២០២៦ របស់យើង នាពេលនេះ។

ជាមួយគ្នានេះ ខ្ញុំសូមគោរពថ្លែងនូវអំណរគុណយ៉ាងជ្រាលជ្រៅបំផុត ជូនចំពោះបណ្តាក្រសួង ស្ថាប័នពាក់ព័ន្ធទាំងអស់ ដែលបានខិតខំប្រឹងប្រែង និងផ្តល់កិច្ចសហការយ៉ាងស្អិតរមួត ប្រកបដោយផ្លែផ្កា ជាមួយអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍។ កិច្ចសហប្រតិបត្តិការដ៏ឧត្តុង្គឧត្តមនេះ បាននិងកំពុងរួម

ចំណែកយ៉ាងសំខាន់ក្នុងការជំរុញ និងចូលរួមអនុវត្ត "គោលនយោបាយជាតិលុបបំបាត់ជំងឺអេដស៍ និងចីរភាពនៃកម្មវិធីអេដស៍ ឆ្នាំ២០២៤-២០២៨" ស្របតាមស្មារតីនៃលិខិតលេខ ៩២៧ សជណ ចុះថ្ងៃទី២៤ ខែតុលា ឆ្នាំ២០២២ របស់ទីស្តីការគណៈរដ្ឋមន្ត្រី រួមនឹងសេចក្តីជូនដំណឹងលេខ ២១៣ សជណ.សសចុះថ្ងៃទី២១ខែកុម្ភៈឆ្នាំ២០១៩ របស់រាជរដ្ឋាភិបាលកម្ពុជា។

បន្ថែមលើនេះ តាមរយៈការទទួលបានការអនុម័តដ៏ខ្ពង់ខ្ពស់លើ សារាចរលេខ ២០ សរ ចុះថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០២៥ របស់រាជរដ្ឋាភិបាល ស្តីពីការជំរុញការប្រើប្រាស់ស្រោមអនាម័យឱ្យបាន ១០០ភាគរយ ហើយខ្ញុំមានជំនឿយ៉ាងមុតមាំថា កិច្ចសហការអន្តរវិស័យ និងការសម្របសម្រួលរវាងក្រសួង-ស្ថាប័ន ក៏ដូចជាផ្នែកពាក់ព័ន្ធទាំងអស់ នឹងកាន់តែមានភាពស៊ីជម្រៅ និងដោះស្រាយបានទាន់ពេលវេលា។ យន្តការនេះនឹងធានាថាការអនុវត្តគោលនយោបាយជាតិបញ្ចប់អេដស៍ត្រូវបានបញ្ចូលទៅក្នុងផែនការសកម្មភាពអាទិភាពនៅគ្រប់វិស័យ ប្រកបដោយប្រសិទ្ធភាព និងបរិយាបន្ន។

**ឯកឧត្តម លោកជំទាវ លោក លោកស្រី នាងកញ្ញា !**

ការចូលរួមយ៉ាងសកម្ម និងប្រកបដោយថាមពលរបស់យើងទាំងអស់គ្នាក្នុងការឆ្លើយតបនេះ គឺជាសក្ខីកម្មដ៏រស់រវើកនៃកិច្ចខិតខំប្រឹងប្រែងរួមគ្នា ស្របតាមស្មារតីនៃយុទ្ធសាស្ត្របញ្ចកោណរបស់រាជរដ្ឋាភិបាលកម្ពុជា ស្របពេលដែលគោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការក្នុងវិស័យសុខាភិបាល បាន និងកំពុងផ្តល់សិទ្ធិអំណាច ព្រមទាំងការទទួលខុសត្រូវពេញលេញដល់រដ្ឋបាលគ្រប់លំដាប់ថ្នាក់ ក្នុងការគ្រប់គ្រងមុខងារ និងធនធានរបស់ខ្លួន។ យន្តការនេះបានបើកផ្លូវឱ្យទាំងរដ្ឋបាលថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ អាចរៀបចំកញ្ចប់ថវិកាពាក់ព័ន្ធនឹងមុខងារប្រគល់មានភ្ជាប់លក្ខខណ្ឌ ក្នុងវិស័យសុខាភិបាលនិងវិស័យអប់រំ ព្រមទាំងអាចដាក់ចេញនូវយន្តការច្នៃប្រឌិតថ្មីៗ ក្នុងការកៀងគរ និងប្រើប្រាស់ធនធានឱ្យចំគោលដៅ ដើម្បីធានាចីរភាពយូរអង្វែងនៃកម្មវិធីឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍នៅកម្ពុជា។

ក្នុងបរិបទនេះ ការរៀបចំផែនការយុទ្ធសាស្ត្រថវិកា ៣ឆ្នាំរំកិល (២០២៧-២០២៩) និងការលើកគម្រោងថវិកាប្រចាំឆ្នាំ២០២៧ ត្រូវតែធ្វើឡើងដោយស្មារតីហ្មត់ចត់ និងទទួលខុសត្រូវខ្ពស់ ស្របតាមសារាចរលេខ ០៦ សរ ចុះថ្ងៃទី១៥ ខែឧសភា ឆ្នាំ២០២៦ របស់រាជរដ្ឋាភិបាល ស្តីពីការរៀបចំផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ២០២៧-២០២៩ និងការរៀបចំសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២៧ ផងដែរ។ក្នុងគោលបំណងបង្កើននូវភាពម្ចាស់លើវឌ្ឍនភាពនៃគុណវិស័យ និងការរៀបចំយន្តការឆ្លើយតបមេរោគអេដស៍ និងជំងឺអេដស៍ អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ បានរៀបចំផែនការយុទ្ធសាស្ត្រ និងអនុវត្តសកម្មភាព រួមទាំងការតាមដាន និងវាយតម្លៃការឆ្លើយតបមេរោគអេដស៍ និងជំងឺអេដស៍។

ផែនការនេះបានផ្តោតសំខាន់លើ គោលដៅ ៩៥-៩៥-៩៥ ចំនួនប្រជាជនគន្លឹះនិងអត្រានៃការប្រើប្រាស់ស្រោមអនាម័យ។ ផែនការយុទ្ធសាស្ត្រដ៏ទូលំទូលាយ គ្របដណ្តប់គ្រប់វិស័យ និងមានលក្ខណៈវែងឆ្ងាយនេះ គឺជាមគ្គុទ្ទេសក៏តម្រង់ផ្លូវ ដែលគោរពយ៉ាងខ្ជាប់ខ្ជួនទៅនឹងផែនការយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ របស់រាជរដ្ឋាភិបាលកម្ពុជា និងសេចក្តីប្រកាសនៃការប្តេជ្ញាចិត្ត ក្នុងការប្រយុទ្ធទប់ស្កាត់ការរាលដាលមេរោគអេដស៍ និងជំងឺអេដស៍របស់រាជរដ្ឋាភិបាល។

ការឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍ជាបញ្ហាសុខភាពសាធារណៈមួយដែលត្រូវការនូវដំណោះស្រាយជាអាទិភាពឆ្ពោះ ទៅសម្រេចបាននូវការគ្របដណ្តប់សុខភាពជាសកល ដូចបានកំណត់ក្នុងផែនទីបង្ហាញផ្លូវឆ្ពោះទៅការគ្របដណ្តប់សុខភាពជាសកលនៅកម្ពុជាឆ្នាំ២០២៤-២០៣៥ ដែលប្រកាសឱ្យអនុវត្តជាផ្លូវការក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** កាលពីព្រឹកថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០២៤។

ក្នុងឋានៈជាស្ថាប័នរបស់រាជរដ្ឋាភិបាល អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ មានតួនាទី ភារកិច្ច និងការ ទទួលខុសត្រូវក្នុងការដឹកនាំគ្រប់គ្រង និងសម្របសម្រួលការអនុវត្តនូវគោលនយោបាយជាតិបញ្ចប់អេដស៍ ប្រកបដោយវឌ្ឍនភាព និងប្រសិទ្ធភាព តាមរយៈការចងក្រងនូវព័ត៌មាន ដោយមានការចូលរួមទូលំទូលាយនិងពហុវិស័យពីស្ថាប័នជាតិ អន្តរជាតិ ឯកជន សង្គមស៊ីវិលនិងក្រុមគោលដៅ។

រហូតមកដល់ពេលនេះនៅក្នុងគោលនយោបាយជាតិបញ្ចប់អេដស៍ដែលមាន គោលនយោបាយចំនួន៧ និងវិធានការចំនួន៥៣ ជាលទ្ធផលបានបង្ហាញថានៅថ្នាក់ជាតិមានក្រសួង-ស្ថាប័នចំនួន៣០ បានធ្វើបច្ចុប្បន្នភាពគណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍ ក្នុងនោះក្រសួង-ស្ថាប័នចំនួន២៥បានរៀបចំ និងបញ្ចូលផែនការសកម្មភាព និងថវិកាឆ្លើយតបនឹងមេរោគអេដស៍ទៅក្នុងផែនការស្នូលរបស់ក្រសួង-ស្ថាប័នខ្លួន ដែលក្នុងនោះមានចំនួន១៥ បានទទួលការអនុម័តថវិកាពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

បន្ថែមពីលើនេះ ក្រសួងសុខាភិបាលដែលមានមជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើរស្បែក និងកាមរោគ ជាសេនាធិការ បាននិងកំពុងរៀបចំនូវឯកសារស្តីពីទិសដៅនៃការអនុវត្តកម្មវិធីដោយភ្នាក់ងារមិនមែនរដ្ឋ ( Non-State Actor ) ដែលជាផ្នែកដ៏សំខាន់មួយទៀត ក្នុងការជួយបំពេញចន្លោះប្រហោង និងចំណុចខ្វះខាតនៃថវិកាដើម្បីអនុវត្តបំពេញសកម្មភាពដែលនៅសេសសល់ ឱ្យបានគ្រប់ជ្រុងជ្រោយ ហើយខ្លឹមសារលម្អិតនៃឯកសារដ៏មានសារៈសំខាន់នេះ ក៏នឹងត្រូវលើកយកមកធ្វើបទបង្ហាញជូនអង្គពិធីទាំងមូល ក្នុងកិច្ចប្រជុំរបស់យើងនាពេលនេះផងដែរ។

## ឯកឧត្តម លោកជំទាវ លោក លោកស្រី នាងកញ្ញា!

កិច្ចប្រជុំពេញអង្គអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ លើកទី១ នេះ ត្រូវបានរៀបចំឡើងក្នុងគោលបំណងសំខាន់ពីរ៖ ទី១ គឺដើម្បីពិនិត្យ និងវាយតម្លៃរួមគ្នានូវវឌ្ឍនភាព សមិទ្ធផល និងប្រសិទ្ធភាព នៃការងារប្រយុទ្ធនឹងជំងឺអេដស៍ សម្រាប់រយៈពេល ៦ ខែដើមឆ្នាំ២០២៦, ទី២ គឺដើម្បីប្រមូល និងពិភាក្សាលើធាតុចូល ព្រមទាំងអនុសាសន៍នានា តាមរយៈការចូលរួមដ៏មានតម្លៃរបស់ ឯកឧត្តម លោកជំទាវអស់លោក លោកស្រី នាងកញ្ញា ដែលមានវត្តមាននាពេលនេះ។

តាមរបៀបវារៈកិច្ចប្រជុំ យើងនឹងមានបទបង្ហាញចំនួន៤ រួមមាន ៖

ទី១. បទបង្ហាញស្តីពីសេចក្តីព្រាងស្តីពីវឌ្ឍនភាព នៃការអនុវត្តសេចក្តីសម្រេចចិត្តនៃកិច្ចប្រជុំពេញអង្គលើកទី២ ឆ្នាំ២០២៥" ដោយ **ឯកឧត្តមបណ្ឌិត ឈឹម ឃិនដារ៉េត** អគ្គលេខាធិការអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍។

ទី២. បទបង្ហាញស្តីពី «ផែនការយុទ្ធសាស្ត្រជាតិឆ្លើយតប នឹងមេរោគអេដស៍និងជំងឺអេដស៍ក្នុងវិស័យសុខាភិបាល» ដោយ **លោកសាស្ត្រាជំនួយ អ៊ុក វិជ្ជា** ប្រធានមជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគ នៃក្រសួងសុខាភិបាល។

ទី៣. បទបង្ហាញស្តីពី «ការចូលរួមរបស់គម្រោងមូលនិធិសកល ក្នុងការអនុវត្តគោលនយោបាយជាតិបញ្ចប់អេដស៍ និងចីរភាពកម្មវិធីអេដស៍ ឆ្នាំ២០២៣-២០២៨» ដោយ **លោកវេជ្ជបណ្ឌិត ជីវ ប៊ុនជី** ប្រធានលេខាធិការដ្ឋាន CCC។

ទី៤. បទបង្ហាញស្តីពី «ទិសដៅ នៃការអនុវត្តកម្មវិធីដោយភ្នាក់ងារមិនមែនរដ្ឋ (Non-State Actor) និងការរៀបចំផែនការរួមសម្រាប់ការឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺ អេដស៍នៅថ្នាក់ក្រោមជាតិ» ដោយ **ឯកឧត្តមវេជ្ជបណ្ឌិត ទា ផលា** អនុប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍។

ជាចុងក្រោយ នឹងមានការអនុម័តសេចក្តីសម្រេចចិត្ត កិច្ចប្រជុំពេញអង្គអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍លើកទី១ ឆ្នាំ២០២៦ ផងដែរ ។

**ឯកឧត្តម លោកជំទាវ លោក លោកស្រី នាងកញ្ញា!**

ជារួម យើងទាំងអស់គ្នារក្សាបាននូវមោទនភាព និងក្តីសង្ឃឹមខ្ពស់ក្នុងការបញ្ចប់ជំងឺអេដស៍ ហើយការប្តេជ្ញាចិត្តនេះ ត្រូវបានអនុវត្តតាមរយៈការពង្រឹងភាពជាម្ចាស់ ភាពជាអ្នកដឹកនាំ និងការសម្របសម្រួលសហការជាចរន្តជាតិតែមួយ ទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដើម្បីពង្រីកសកម្មភាពឆ្លើយតបទ្វេដង។ទន្ទឹមនឹងនេះ យើងក៏នឹងពង្រឹងប្រព័ន្ធតាមដាន និងវាយតម្លៃជាតិ ដើម្បីធានាបាននូវព័ត៌មានគ្រប់ជ្រុងជ្រោយ រក្សាបាននូវចីរភាពនៃការឆ្លើយតបជាពហុវិស័យ ពីគ្រប់ស្ថាប័ន ជាតិ អន្តរជាតិ ដៃគូអភិវឌ្ឍន៍ សង្គមស៊ីវិល វិស័យឯកជន ជាពិសេសបណ្តាញអ្នកផ្ទុកមេរោគអេដស៍ ហើយយើងបង្កើតបាននូវស្ថាប័នដឹកនាំគ្រប់គ្រងនិងសម្របសម្រួលតែមួយទាំងនៅថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ ជាពិសេសមានផែនការយុទ្ធសាស្ត្រជាតិតែមួយ មានប្រព័ន្ធតាមដាន និងវាយតម្លៃជាតិតែមួយប្រកបដោយប្រសិទ្ធភាពខ្ពស់ ។

**ឯកឧត្តម លោកជំទាវ លោក លោកស្រី នាងកញ្ញា!**

ខ្ញុំមានជំនឿយ៉ាងមុតមាំថា លទ្ធផលដែលទទួលបានពីកិច្ចប្រជុំនេះ នឹងមានសារៈសំខាន់ជាចម្បង ដោយអាចផ្តល់នូវទិន្នន័យចាំបាច់ដល់ក្រុមការងារបច្ចេកទេស សម្រាប់យកទៅបន្តអនុវត្តការងារឆ្លើយតបទៅនឹងការរាលដាលមេរោគអេដស៍ និងជំងឺអេដស៍នៅពេលខាងមុខ ឱ្យស្របតាមអនុសាសន៍ដែលនឹងត្រូវផ្តល់ជូនក្នុងកិច្ចប្រជុំពេញអង្គនាពេលបន្តិចទៀតនេះ។

ដើម្បីទុកពេលវេលាឱ្យបានច្រើនសម្រាប់ការធ្វើបទបង្ហាញ និងការពិភាក្សាផ្លាស់ប្តូរយោបល់ និងបទពិសោធន៍ការងារពីសំណាក់បណ្តា សមាជិក សមាជិកាអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ខ្ញុំសូមបញ្ចប់សុន្ទរកថាបើកកិច្ចប្រជុំនាពេលនេះ។ ខ្ញុំសូមប្រសិទ្ធពរជ័យជូន ឯកឧត្តម លោកជំទាវ លោក លោកស្រី នាងកញ្ញាទាំងអស់ សូមមានសុខភាពល្អ កម្លាំងពលំមាំមួន និងប្រាជ្ញាវាងវៃ ដើម្បីចូលរួមពិភាក្សា

ទទួលបានជោគជ័យតាមកម្មវត្ថុដែលបានគ្រោងទុក និងសូមប្រកាសបើក "**កិច្ចប្រជុំពេញអង្គអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍លើកទី១ ឆ្នាំ២០២៦**" ចាប់ពីពេលនេះតទៅ។

**សូមអរគុណ**!